ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៩១/១១-ឃ្វីកស៊ូ**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **សេង រ៉ូចហ៊ុន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **អាំង អេងថុង**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន ឃ្វីកស៊ូ (ខេមបូឌា)**

អាសយដ្ឋាន : ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៩៨៩ ២៨៩ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក ណួន ណួយ រដ្ឋបាលក្រុមហ៊ុន

២- លោក ឃាង ស៊ីវខេង ជំនួយការផ្នែកផលិតកម្ម

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : - **សម្ព័ន្ធសហជីពចលនាកម្មករ**

- **សហជីពចលនាកម្មករនៃរោងចក្រកាត់ដេរ ឃ្វីកស៊ូ**

អាសយដ្ឋាន : ផ្ទះលេខ ១៥ C2 ផ្លូវវែងស្រេង ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១៧ ៨៨៣ ០៤០ ទូរសារ : គ្មាន


ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត:

| | |
|---|---|
| ១- លោក ឡុង តៅស៊ាន់ | មន្ត្រីសម្ព័ន្ធសហជីពចលនាកម្មករ |
| ២- លោក ទុយ វ៉ាង | មន្ត្រីសម្ព័ន្ធសហជីពចលនាកម្មករ |
| ៣- លោក ទូន សារ៉ែន | មន្ត្រីសម្ព័ន្ធសហជីពចលនាកម្មករ |
| ៤- លោកស្រី ឈន ស៊ីម៉េង | ប្រធានសហជីពចលនាកម្មករនៃរោងចក្រកាត់ដេរ ឃ្វីកស៊ូ |
| ៥- កញ្ញា ភាព សុភា | សកម្មជន |
| ៦- កញ្ញា ញឹម សារ៉េត | សកម្មជន |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ថ្នាក់ដឹកនាំសហជីពចលនាកម្មករប្រចាំក្រុមហ៊ុន ឃ្វីកស៊ូ នៅតែទាមទារឱ្យក្រុមហ៊ុនទទួលយក អ្នកស្រី ឃន ស៊ីម៉េង ដែលជាប្រធានសហជីពចលនាកម្មករ (ថ្នាក់ដឹកនាំថ្មី) ប្រចាំក្រុមហ៊ុន ឃ្វីកស៊ូ ចូលធ្វើការជាធម្មតាវិញ។ ដោយឡែកភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចទទួលយកចូលធ្វើការវិញបានទេ ដោយហេតុថា ក្រុមហ៊ុនពុំបានដឹងមុនថា អ្នកស្រី ឃន ស៊ីម៉េង ជាថ្នាក់ដឹកនាំសហជីពឡើយ ហើយមូលហេតុដែលក្រុមហ៊ុនបញ្ឈប់អ្នកស្រី ដោយសារតែអ្នកស្រីធ្វើការផ្ទាល់ខ្លួនក្នុងម៉ោងការងារច្រើនពេក (កេងប្រវ័ញ្ច)។

២- ថ្នាក់ដឹកនាំសហជីពចលនាកម្មករប្រចាំក្រុមហ៊ុន ទាមទារឱ្យក្រុមហ៊ុនកាត់ប្រាក់ភាគទានពីសមាជិក ដើម្បីបង់ឱ្យសម្ព័ន្ធសហជីពចលនាកម្មករ ដោយហេតុថា ការកាត់ប្រាក់ភាគទាននេះ ធ្លាប់បានកាត់ឱ្យជិតមួយឆ្នាំហើយ។ ដោយឡែកភាគីក្រុមហ៊ុនមិនអាចកាត់ឱ្យបានឡើយ ដោយហេតុថា មានថ្នាក់ដឹកនាំសហជីពចាស់បានយកលិខិតពីសហព័ន្ធផ្សេងមកដាក់ឱ្យក្រុមហ៊ុនសុំឱ្យក្រុមហ៊ុនឈប់កាត់ប្រាក់ភាគទាននេះតទៅទៀត។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៩)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៨១៨ ក.ប/អក/វ.ក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១១។

THE ARBITRATION COUNCIL

## សវនាការ និង សន្ទេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១ ( វេលាម៉ោង ០៨:៣០ នាទី ព្រឹក ) ។

**បញ្ហានៃនីតិវិធីៈ**

នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សម្ព័ន្ធសហជីពចលនាកម្មករ លេខ ០៤២/១១ សសចក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទរួមនេះជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០២ ចំណុច លើការទាមទារចំនួន ០៤ ចំណុច ។ ចំណុចវិវាទ ដែលមិនសះជានឹងគ្នាចំនួន ០២ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១១ តាមរយៈរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៨១៨ កប/អក/វក ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១១ ។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១ វេលាម៉ោង ០៨:៣០ នាទី ព្រឹក នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន០២ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជាចំនួន១ចំណុច គឺចំណុចវិវាទទី២ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា និងដោះស្រាយចំណុចវិវាទមិនសះជាចំនួន០១ ចំណុចខាងលើ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោមៈ

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី :

## ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរ និងទទួលសិទ្ធិ របស់ក្រុមហ៊ុន ឃ្វីកស៊ូ ផ្ទេរសិទ្ធិជូន លោក ណូន ណួយ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១១ ។

២- សេចក្តីប្រកាសរបស់ក្រុមហ៊ុន ឃ្វីកស៊ូ ស្តីពីការសំគាល់ និងការទប់ស្កាត់បុគ្គលមិនស្គាល់អត្តសញ្ញាណ និងទទួលប្រអប់សំបុត្រ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១០។

៣- តារាងបុគ្គលិកសន្តិសុខ CSC ប្រចាំក្រុមហ៊ុន ឃ្វីកស៊ូ វេនថ្ងៃ ចុះថ្ងៃទី១ ខែឧសភា ឆ្នាំ២០១១។

៤- មតិប្រធានគ្រប់គ្រង ស្តីពីការមិនបន្តកិច្ចសន្យារបស់អ្នកស្រី ខន ស៊ីម៉េង។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- សារណាសង្ខេបស្តីពីវិវាទការងារនៅក្រុមហ៊ុន ឃ្វីកស៊ូ របស់សម្ព័ន្ធសហជីពចលនាកម្មករ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១១។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពចលនាកម្មករ នៃរោងចក្រកាត់ដេរ ឃ្វីក ស៊ូ ចុះបញ្ជិកាលេខ ១៨៨៨ កប/វក. ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០។

៣- លិខិតរបស់សម្ព័ន្ធសហជីពចលនាកម្មករ គោរពជូន លោកនាយករោងចក្រកាត់ដេរ ឃ្វីក ស៊ូ ស្តីពីការជូនដំណឹងអំពីថ្នាក់ដឹកនាំសហជីពចលនាកម្មករថ្មីនៃរោងចក្រកាត់ដេរ ឃ្វីកស៊ូ លេខ ០៣២/០១ សសចក ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១១។

៤- លិខិតលាលែងរបស់ឈ្មោះ កាន់ សុភាធន ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១ ស្តីពីការលាលែងពីសម្ព័ន្ធសហជីពចលនាកម្មករ។

៥- លិខិតលាលែងរបស់ឈ្មោះ រ៉ាយ រតនា ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១ ស្តីពីការលាលែងពីសម្ព័ន្ធសហជីពចលនាកម្មករ។

៦- លិខិតរបស់សម្ព័ន្ធសហជីពចលនាកម្មករ គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការប្តឹងនាយកក្រុមហ៊ុនកាត់ដេរ ឃ្វីក ស៊ូ ស្តីពីការរើសអើងសហជីព លេខ ០៤២/០១ សសចក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១។

៧- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារ ជំរាបមក អ្នកស្រីប្រធានសហជីពចលនាកម្មករ នៃរោងចក្រកាត់ដេរ ឃ្វីក ស៊ូ ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី លេខ ៦៥៦ ក.ប/អក/វក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១។

៨- លិខិតស្នើសុំរបស់ថ្នាក់ដឹកនាំសហជីពចលនាកម្មករ និងកម្មករ-កម្មការិនីប្រចាំរោងចក្រកាត់ដេរ ឃ្វីក ស៊ូ គោរពជូនលោកប្រធានសម្ព័ន្ធសហជីពចលនាកម្មករ ស្តីពីស្នើសុំជួយដោះស្រាយនូវលក្ខខណ្ឌការងារមួយចំនួន ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១១។

៩- លិខិតរបស់សម្ព័ន្ធសហជីពចលនាកម្មករ គោរពជូន លោកអគ្គនាយករោងចក្រកាត់ដេរ ឃ្វីក ស៊ូ ស្តីពីការសុំជួបពិភាក្សាជាមួយលោកអគ្គនាយក នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ វេលាម៉ោង ១:០០

នាទី វសៀល ទាក់ទងនឹងសំណើរមួយចំនួន លេខ ០៤៨/១១ សសចក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០១១។

១០- លិខិតរបស់សម្ព័ន្ធសហជីពចលនាកម្មករ គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការប្តឹងនាយកក្រុមហ៊ុនកាត់ដេរ ឃ្វីក ស៊ូ ស្តីពីការរើសអើងសហជីពលេខ ០៥០/០១ សសចក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១។

១១- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ឃ្វីក ស៊ូ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១។

១២- លិខិតជូនដំណឹងធ្វើកូដកម្មរបស់គណៈកម្មាធិការសហជីពចលនាកម្មករប្រចាំរោងចក្រកាត់ដេរ ឃ្វីក ស៊ូ គោរពជូន លោកអគ្គនាយកក្រុមហ៊ុនកាត់ដេរ ឃ្វីក ស៊ូ ស្តីពីការជូនដំណឹងធ្វើកូដកម្ម ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១១។

១៣- លិខិតរបស់សម្ព័ន្ធសហជីពចលនាកម្មករ គោរពជូន លោកប្រធានមជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាព ស្តីពីសុំជួយអន្តរាគមន៍ ករណីក្រុមហ៊ុន ឃ្វីក ស៊ូ បញ្ឈប់ថ្នាក់ដឹកនាំសហជីព ដែលជាសកម្មភាពរើសអើងសហជីព លេខ ០៥២/០១ សសចក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១។

១៤- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ឃ្វីកស៊ូ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ ២០១១។

១៥- តារាងប្រាក់ឈ្នួល របស់កម្មករឈ្មោះ មាន ស័ង្កលី។

១៦- លិខិតលាលែងរបស់ឈ្មោះ លីម ចាន់ថា ស្តីពីការលាលែងពីសម្ព័ន្ធសហជីពចលនាកម្មករ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១១។

១៧- លិខិតលាលែងរបស់ឈ្មោះ ណា ភារម្យ ស្តីពីការលាលែងពីសម្ព័ន្ធសហជីពចលនាកម្មករ ចុះថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១១។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឃ្វីក ស៊ូ លេខ ៨១៨ កប/អក/វក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ឃ្វីក ស៊ូ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញនាយកក្រុមហ៊ុន ឃ្វីក ស៊ូ ចូលរួមសវនាការលេខ ៥១៨ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១។

THE ARBITRATION COUNCIL

២- លិខិតអញ្ជើញសហជីពចលនាកម្មករប្រចាំរោងចក្រកាត់ដេរ ឃ្វីក ស៊ូ ចូលរួមសវនាការ លេខ ៥១៩ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- តាមរយៈរបាយការណ៍មិនសះជាក្រុមហ៊ុន ឃ្វីក ស៊ូ គឺជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់។
- ក្រុមហ៊ុននេះជួលកម្មករនិយោជិតសរុបប្រហែល ១ ៣២០ នាក់។
- សហជីពចលនាកម្មករ គឺជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។

**ចំណុចវិវាទទី ១ : កម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកអ្នកស្រី ឃន ស៊ីម៉េង ដែលជាប្រធានសហជីពប្រចាំក្រុមហ៊ុនចូលធ្វើការវិញ**

- អ្នកស្រី ឃន ស៊ីម៉េង ចាប់ផ្តើមចូលធ្វើការដំបូងនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ ដែលមានកិច្ចសន្យាកំណត់ថិរវេលាចំនួន ៣ ខែម្តង ហើយដែលមានតួនាទីជាអ្នកដេរ។ បន្ទាប់មក និយោជកបានប្តូរកិច្ចសន្យារបស់គាត់ឱ្យមករយៈពេល ៦ ខែ វិញ។ កិច្ចសន្យាចុងក្រោយរបស់គាត់ត្រូវដល់កាលកំណត់ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១។
- អ្នកស្រី ឃន ស៊ីម៉េង ត្រូវបានក្រុមហ៊ុនបញ្ចប់កិច្ចសន្យាមុនកាលកំណត់នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ ២០១១។ កន្លងមក អ្នកស្រី ឃន ស៊ីម៉េង ធ្លាប់ទទួលការព្រមានផ្ទាល់មាត់ម្តងនៅក្នុងខែមេសា ឆ្នាំ ២០១១ អំពីការនិយាយទូរសព្ទ័នៅពេលកំពុងធ្វើការ។ ប៉ុន្តែ អ្នកស្រីពុំដែលទទួលការព្រមានជាលាយលក្ខណ៍អក្សរណាមួយទេ។
- អ្នកស្រី ឃន ស៊ីម៉េង មានតួនាទីជាប្រតិភូជំនួយនៅក្នុងរោងចក្រ និងធ្លាប់ចូលរួមប្រជុំជាមួយមន្ត្រីអាយឡូ (ILO) ស្តីពីលក្ខខណ្ឌការងារទូទៅនៅក្នុងក្រុមហ៊ុនដេរ។
- អ្នកស្រី ឃន ស៊ីម៉េង បានលើកឡើងថា នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ ប្រហែលជាម៉ោង ៣:៤៥ នាទី សន្តិសុខក្រុមហ៊ុនបានហៅគាត់ទៅជួបរដ្ឋបាល។ មន្ត្រីរដ្ឋបាលបានប្រាប់គាត់ថា ក្រុមហ៊ុនពុំមានការងារធ្វើទៀតទេ ហើយក្រុមហ៊ុនចាំបាច់ត្រូវបញ្ឈប់គាត់មុនកិច្ចសន្យាដល់ការកំណត់។ ពេលនោះ មន្ត្រីរដ្ឋបាលក៏

THE ARBITRATION COUNCIL

សុំដកហូតកាតពីគាត់តែម្តង។ ក្នុងការបញ្ឈប់នេះ និយោជកពុំបានជូនដំណឹងមុនទេ ហើយនិយោជក ក៏ពុំបានជូនដំណឹង ស្តីពីការបញ្ឈប់នេះទៅអធិការការងារដែរ។

- អ្នកស្រី ឃន ស៊ីម៉េង បានលើកឡើងថា ក្រៅពីតួនាទីជាប្រតិភូជំនួយ អ្នកស្រីមានតួនាទីមួយទៀតជាប្រធានសហជីពចលនាកម្មករប្រចាំក្រុមហ៊ុន ដែលត្រូវបានតែងតាំងថ្មីនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១១។ សហជីពបានជូនដំណឹងពីបេក្ខភាពនេះ ទៅនិយោជកនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១១ ហើយមានសន្តិសុខក្រុមហ៊ុន ជាអ្នកចុះហត្ថលេខាទទួល។ ទន្ទឹមនឹងនេះដែរ នៅខែឧសភា ឆ្នាំ២០១១ អ្នកស្រីក៏ធ្លាប់ជាតំណាងកម្មករនិយោជិតចូលរួមប្រជុំជាមួយមន្ត្រី អាយឡូ (ILO) ស្តីពីលក្ខខណ្ឌការងារទូទៅនៅក្នុងក្រុមហ៊ុនដែរ។
- ភាគីនិយោជកបានលើកឡើងថា ទាក់ទងទៅនឹងការបញ្ឈប់កិច្ចសន្យារបស់អ្នកស្រី ឃន ស៊ីម៉េង គឺដោយសារការងាររបស់គាត់ពុំសូវល្អ ដូចជាបានលក់សំលៀកបំពាក់ និងបំរើទូរស័ព្ទសាធារណៈជូនកម្មករនិយោជិតនៅក្នុងក្រុមហ៊ុន ហើយកន្លងមកអ្នកស្រីក៏ធ្លាប់ទទួលការព្រមានម្តងដែរ ស្តីពីការនិយាយទូរស័ព្ទនៅក្នុងម៉ោងធ្វើការ។ ទន្ទឹមនឹងនេះដែរ នៅក្នុងក្រុមហ៊ុន ក៏ពុំសូវមានការងារធ្វើទៀត ជាពិសេសចាប់ពីខែឧសភា ទៅខែសីហា។
- ភាគីនិយោជកបានបញ្ជាក់ថា និយោជកពុំដែលធ្វើការព្រមានអ្នកស្រី ឃន ស៊ីម៉េង ទេ។ ទាក់ទងទៅនឹងការបញ្ឈប់នេះ និយោជកបានទូទាត់ប្រាក់ឈ្នួលជូនគាត់ទៅតាមច្បាប់ស្តីពីការងារ ប៉ុន្តែអ្នកស្រីពុំទាន់យល់ព្រមទទួលនៅឡើយទេ។ ហើយការបញ្ឈប់នេះដែរ និយោជកក៏ពុំបានដឹងថា អ្នកស្រី ឃន ស៊ីម៉េង ជាប្រធានសហជីពដែរ ពោលនិយោជកពុំបានទទួលការជូនដំណឹងណាមួយពីសមាសភាពអ្នកស្រីទេ។

## ហេតុផលនៃសេចក្តីសម្រេចៈ

### ចំណុចវិវាទទី១: កម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកអ្នកស្រី ឃន ស៊ីម៉េង ដែលជាប្រធានសហជីពប្រចាំក្រុមហ៊ុនចូលធ្វើការវិញ

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាដូចខាងក្រោមនេះ:

មាត្រា ២៩៣ នៃច្បាប់ស្តីពីការងារបានចែងថា *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាមួយពីការងាររបស់ខ្លួន អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ ។...*

*អធិការការងារដែលបានទទួលពាក្យបណ្តឹងសុំបញ្ឈប់កម្មករនិយោជិតដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តល់សេចក្តីសម្រេចរបស់ខ្លួនដល់និយោជក ដល់កម្មករនិយោជិតដែលត្រូវបញ្ឈប់ ...ក្នុងរយៈពេលមួយខែយ៉ាងយូរក្រោយពីទទួលពាក្យបណ្តឹង ។...*

THE ARBITRATION COUNCIL

*បើគ្មានការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អធិការការងារ ក្នុងរយៈពេលដែលបានកំណត់ឱ្យទេ...ពាក្យបណ្តឹង ...ត្រូវចាត់ទុកថាបានបដិសេធចោល* "។

តាមខ្លឹមសារ នៃមាត្រា ២៩៣ រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ដែលទទួលបានការការពារ និយោជកត្រូវមានការអនុញ្ញាតពីអធិការការងារ និងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យការងារ។ មានន័យថា អធិការការងារ ដែលបានទទួលពាក្យបណ្តឹងសុំបញ្ឈប់កម្មករនិយោជិត ដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តល់សេចក្តីសម្រេចរបស់ខ្លួនដល់និយោជក និងដល់កម្មករនិយោជិត ដែលត្រូវបញ្ឈប់ពីការងារ ឬមិនបញ្ឈប់ពីការងារក៏ដូចជាដល់អង្គការសហជីពដែលគ្រប់គ្រងកម្មករនិយោជិតនោះ ក្នុងរយៈពេលមួយខែយ៉ាងយូរក្រោយទទួលពាក្យបណ្តឹង។

យោងទៅតាមអង្គហេតុ អ្នកស្រី ឃន ស៊ីម៉េង គឺជាប្រតិភូជំនួយ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើប្រតិភូជំនួយ តាមមាត្រា ២៩៣ នេះ គឺជាប្រតិភូបុគ្គលិក ដែលទទួលបានការការពារដែរ ឬទេ?

ប្រការ ១ នៃប្រកាសលេខ ២៨៦ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០១ បានចែងថា "*សហគ្រាសគ្រឹះស្ថានទាំងអស់ ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ហើយដែលមានប្រើកម្មករនិយោជិតចាប់ពី ០៨ នាក់ឡើងទៅ ត្រូវបង្កើតឱ្យមានប្រតិភូបុគ្គលិក។ ប្រតិភូពេញសិទ្ធិ (ឬប្រតិភូបុគ្គលិកពេញសិទ្ធិ) ម្នាក់ ត្រូវមានប្រតិភូជំនួយម្នាក់។*

*... ប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយ ត្រូវបោះឆ្នោតជ្រើសរើស ដោយកម្មករនិយោជិតសម្រាប់អណត្តិ ២ឆ្នាំ...*"។

យោងតាមប្រការខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយ គឺជាប្រតិភូបុគ្គលិក ហើយតួនាទីនេះ ត្រូវបានបោះឆ្នោតដោយកម្មករនិយោជិតសម្រាប់អណត្តិ ២ ឆ្នាំ។ ដូចនេះ ប្រតិភូជំនួយក៏ត្រូវបានទទួលការការពារតាមមាត្រា ២៩៣ ខាងលើនេះដែរ។

តាមរយៈអង្គហេតុ ភាគីនិយោជកបានបញ្ឈប់អ្នកស្រី ឃន ស៊ីម៉េង ដែលមានតួនាទីជាប្រតិភូជំនួយពីការងារ ដោយមិនបានជូនដំណឹង និងបានទទួលការយល់ព្រមពីអធិការការងារទេ។ ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកគួរតែមានការជូនដំណឹង និងត្រូវមានការយល់ព្រមពីអធិការការងារជាមុនសិនមុនពេលសម្រេចបញ្ឈប់អ្នកស្រី ឃន ស៊ីម៉េង ព្រោះគាត់ត្រូវទទួលបានការការពារចំពោះការបញ្ឈប់ពីការងារ។ ដូចនេះ ការបញ្ឈប់នេះ គឺធ្វើឡើងមិនត្រឹមត្រូវតាមនីតិវិធីច្បាប់ស្តីពីការងារនៅឡើយទេ។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកទទួលយកកម្មករនិយោជិត ដែលទទួលបានការការពារចំពោះការបញ្ឈប់ពីការងារឱ្យចូលធ្វើការវិញ នៅពេលនិយោជកមិនបានសុំការអនុញ្ញាតពីអធិការការងារ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៧១/០៩-ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ និងលេខ ០៩/១០-ជុង ហាវ)* ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឱ្យនិយោជកទទួលយកអ្នកស្រី ឃន ស៊ីម៉េង ចូលធ្វើការនៅកន្លែងដើមវិញ និងគិតប្រាក់រំលឹកចាប់ពីថ្ងៃ ដែលនិយោជកបញ្ឈប់ ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ :

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ :** បង្គាប់ឱ្យនិយោជកទទួលយកអ្នកស្រី ឃន ស៊ីម៉េង ចូលធ្វើការនៅកន្លែងដើមវិញ និងគិតប្រាក់រំលឹកចាប់ពីថ្ងៃ ដែលនិយោជកបញ្ឈប់ ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **សេង ឱ្ជចហ៊ិន**

ហត្ថលេខា: ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **អន ណាន**

ហត្ថលេខា: ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **អាំង អេងថុង**

ហត្ថលេខា: ------------------------------

THE ARBITRATION COUNCIL